សលាកប័ត្រព័ត៌មាន៖ កម្រងឯកសារស្តីពីករណីសិក្សា ៖ សោដនាដកម្មនៅបុរីកីឡានៅតែបន្តកើតមាន
កាលបរិច្ឆេទ៖ ចាប់ពីខែមករា ឆ្នាំ២០១២ រហូតដល់បច្ចុប្បន្ន
រូបភាពរួម៖ ករណីកើតឡើងនៅបុរីកីឡា គឺជាករណីមួយក្នុងចំណោមករណីជាច្រើន ដែលបានកើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) ដែលបង្ហាញថា ការមិនអើពើទាល់តែសោះចំពោះសហគមន៍ក្រីក្រ ពីសំណាក់អាជ្ញាធរ និងក្រុមហ៊ុនដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធិជាមួយអ្នកមានអំណាច បានបង្កទុក្ខលំបាកវេទនា និងអន្តរាយកាន់តែខ្លាំងឡើងដល់ប្រជាពលរដ្ឋ ដែលសិទ្ធិរបស់ពួកគេមិនត្រូវបានគោរព និងការពារឡើយ ។

សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ បង្ហាញរូបភាពរួមមួយអំពីវិបត្តិមនុស្សធម៌ ដែលប្រជាពលរដ្ឋត្រូវបានគេបណ្តេញចេញពីលំនៅដ្ឋាន កំពុងជួបប្រទះក្នុងតំបន់ដែលពួកគេបានតាំងទីលំនៅថ្មី បន្ទាប់ពីការបណ្តេញចេញដោយបង្ខំនៅខែមករា ឆ្នាំ២០១២ នៅភូមិបុរីកីឡាក្នុងរាជធានីភ្នំពេញ ។ វិបត្តិនេះបានបណ្តាលឲ្យទារកអាយុ៩ខែម្នាក់បាត់បង់ជីវិត ។ ស្ថានភាពដ៏លំបាកវេទនានៅតំបន់ដែលប្រជាពលរដ្ឋតាំងទីលំនៅថ្មី និងភូមិបុរីកីឡាផ្ទាល់ គឺជាឧទាហរណ៍បង្ហាញពីការមិនគោរពតាមមាត្រដ្ឋានអន្តរជាតិទាល់តែសោះ ពីសំណាក់អាជ្ញាធរ និងក្រុមហ៊ុនចំពោះការការពារសិទ្ធិមនុស្ស ដែលទាក់ទងនឹងការបណ្តេញចេញ ។ សលាកប័ត្រនេះត្រូវបានតាក់តែងឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅប្រទេសកម្ពុជា ។

សាវតារករណី

បុរីកីឡាជាតំបន់មួយនៅចំកណ្តាលទីក្រុងភ្នំពេញ ដែលមានផ្ទៃដី១៤,១២ហិចតា និងធ្លាប់ជាលំនៅដ្ឋានរបស់ប្រជាពលរដ្ឋចំនួន១.៧៧៦គ្រួសារ ។ នៅឆ្នាំ២០០៣ ដីសម្បទានសង្គមក្នុងតំបន់បុរីកីឡាចំនួន៤,៦ហិចតា ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា (“រ.ដ.ក”) ផ្តល់ឲ្យក្រុមហ៊ុនឯកជនមួយឈ្មោះ ក្រុមហ៊ុនជានអ៊ីមិច (“ជានអ៊ីមិច”) ។ តាមរយៈកិច្ចព្រមព្រៀង ជានអ៊ីមិចបានចុះកិច្ចសន្យាសាងសង់អគារចំនួន១០លើផ្ទៃដីចំនួនពីរហិចតា ក្នុងគោលបំណងសង្គមដើម្បីផ្តល់ជាផ្ទះសម្បែងដល់ប្រជាពលរដ្ឋក្នុងតំបន់បុរីកីឡា ។ ជាការតបស្នង ជានអ៊ីមិចទទួលបានសិទ្ធិអភិវឌ្ឍន៍លើដីសម្បទានចំនួន២,៦ហិចតាដែលនៅសេសសល់ ។

ក្នុងខែមេសា ឆ្នាំ២០១០ បន្ទាប់ពីបានសាងសង់អគារលំនៅដ្ឋានចំនួនប្រាំបី ក្នុងចំណោមអគារលំនៅដ្ឋានចំនួនដប់ ក្រុមហ៊ុនជានអ៊ីមិចបានសុំការអនុញ្ញាតិពី រ.ដ.ក មិនចាំបាច់សាងសង់អគារចំនួនពីរដែលមិនទាន់បានសង់ ដោយអះអាងថាខ្លួនមិនមានថវិកាគ្រប់គ្រាន់ក្នុងការសាងសង់ ហើយស្នើសុំដីដែលទុកសម្រាប់សាងសង់អគារទាំងពីរនោះ ។ ការខកខានមិនបានសាងសង់អគារទាំងពីរ បណ្តាលឲ្យប្រជាពលរដ្ឋ៣០០ទៅ៤០០គ្រួសារ កង្វះទីលំនៅអចិន្ត្រៃយ៍ ។ នៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២ គ្រួសារជាច្រើនដែលបន្តរស់នៅក្នុងតំបន់បុរីកីឡាត្រូវបានគេបណ្តេញចេញទាំងបង្ខំ ពីលំនៅដ្ឋានរបស់ពួកគេដោយកងកម្លាំងចម្រុះនៃនគរបាល យោធា បុគ្គលិកក្រុមហ៊ុន និងសន្តិសុខជាង១០០នាក់ ។ ផ្ទះសម្បែងជាង២០០ ត្រូវបានកំទេច ។ កងកម្លាំងចម្រុះក៏បានប្រទូសរ៉ាយដោយហិង្សា ជាមួយនឹងប្រជាពលរដ្ឋក្នុងសហគមន៍ ។ នគរបាល និងប្រជាពលរដ្ឋក្នុងសហគមន៍មួយចំនួនត្រូវបានគេរាយការណ៍ថាបានរងរបួស ហើយក្រោយមកប្រជាពលរដ្ឋមួយចំនួនត្រូវបាននគរបាលចាប់ និងឃុំខ្លួន ។

ស្ថានភាពក្នុងតំបន់ដែលប្រជាពលរដ្ឋតាំងទីលំនៅថ្មី

ដោយមិនបានទទួលលំនៅដ្ឋានអចិន្ត្រៃយ៍ ដែលជាសំណងនៃការបណ្តេញចេញពីផ្ទះសម្បែងដោយបង្ខំ ក្រុមគ្រួសារភាគច្រើនបានទៅតាំងទីលំនៅក្នុងតំបន់ដាច់ស្រយាលពីរកន្លែង ដែលមួយកន្លែងស្ថិតនៅទួលសំបូរ ចម្ងាយ២៥គីឡូម៉ែត្រពីទីក្រុងភ្នំពេញ ក្នុងសង្កាត់ព្រៃវែង និងមួយកន្លែងទៀតនៅស្រះពោធិ៍ ដែលត្រូវបានគេស្គាល់ថាភ្នំបាត ក្នុងខេត្តកណ្តាល ។ រហូតមកដល់ពេលនេះ ប្រជាពលរដ្ឋដែលត្រូវគេបណ្តេញចេញ មិនទាន់បានទទួលសំណង ឬការរៀបចំផ្ទះសម្បែងសមស្របនៅឡើយទេ បន្ទាប់ពីពួកគេត្រូវបានបណ្តេញចេញនៅថ្ងៃទី០៣ ខែមករា ឆ្នាំ២០១២ ។ ស្ថានភាពក្នុងតំបន់តាំងទីលំនៅថ្មីមានសភាពលំបាកវេទនា ដោយប្រជាពលរដ្ឋរស់នៅក្រោមក្រណាត់តង់ជាបណ្តោះអាសន្ន មិនមានអគ្គិសនីប្រើប្រាស់ អនាម័យ ទឹកបរិភោគ សាលារៀន ឬឱកាសការងារឡើយ ។

យោងតាមអង្គការលើកលែងទោសអន្តរជាតិ រហូតដល់ខែកុម្ភៈ ឆ្នាំ២០១២ ក្រុមគ្រួសារប្រមាណ១២៥បានបដិសេធមិនព្រមតាំងទីលំនៅថ្មី នៅតំបន់ទាំងពីរដែលនៅឆ្ងាយពីទីក្រុងភ្នំពេញឡើយ ហើយបានបន្តរស់នៅក្នុង និងក្បែរតំបន់ដែលពួកគេត្រូវបានគេបណ្តេញចេញ ក្នុងស្ថានភាពលំបាកវេទនាដូចគ្នា ។ ក្នុងកំឡុងទស្សនកិច្ចថ្មីៗនេះ ទៅកាន់តំបន់ដែលគេបណ្តេញប្រជាពលរដ្ឋចេញ អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិអំពីសិទ្ធិមនុស្សនៅប្រទេសកម្ពុជា លោកសុរិយា

ប្រាសាទ ស៊ូវ៉ែចឌី បានបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំងចំពោះស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយបានហៅស្ថានភាពនេះថាជាវិបត្តិមនុស្សធម៌ ។

នៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១២ ទារកអាយុ៩ខែម្នាក់បានស្លាប់នៅមន្ទីរពេទ្យគន្ធបុប្ផា បន្ទាប់ពីទារកនោះត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដោយសារជម្ងឺរាគ និងក្តៅខ្លួន ដោយហេតុថាក្រុមគ្រួសាររបស់ទារក ត្រូវបានគេបណ្តេញចេញទាំងបង្ខំពីតំបន់បុរីកីឡា ។ ទារកប្រុសនោះបានធ្លាក់ខ្លួនឈឺដោយសារស់នៅក្នុងជីវភាពលំបាកវេទនា រួមមានកង្វះខាតលំនៅដ្ឋាន សមស្រប អាហារ និងសេវាកម្ម ក្នុងតំបន់តាំងទីលំនៅថ្មីនៅស្រះពោធិ៍ ។ យោងតាមអ្នកតំណាងមួយរូបរបស់សហគមន៍ដែលត្រូវគេបណ្តេញចេញពីតំបន់បុរីកីឡា ជីវភាពរស់នៅដ៏លំបាកវេទនាក្នុងតំបន់ដែលពួកគេតាំងទីលំនៅថ្មី បានបណ្តាលឲ្យកុមារ និងមនុស្សចាស់ជរាជាច្រើននាក់ធ្លាក់ខ្លួនឈឺ ។ ប្រសិនបើស្ថានភាពក្នុងតំបន់ដែលពួកគេតាំងទីលំនៅថ្មី មិនមានភាពប្រសើរឡើងទេនោះ ឬប្រសិនបើអ្នកដែលត្រូវបានគេបណ្តេញចេញមិនបានតាំងទីលំនៅក្នុងតំបន់ដែលអាចឲ្យគេរស់នៅបានទេ វានឹងបង្កឲ្យមានហានីភ័យដ៏ធ្ងន់ធ្ងរដែលក្រុមគ្រួសារកាន់តែច្រើនដែលត្រូវបានគេបណ្តេញចេញពីបុរីកីឡា នឹងជួបសោដនាដកម្មប្រហាក់ប្រហែលគ្នា ដែលសោដនាដកម្មទាំងនេះអាចត្រូវបានការពារមិនឲ្យកើតមានឡើងដោយងាយ ។

អំពើហិង្សាដែលកើតឡើងជាញឹកញាប់

ជាអកុសល ករណីកើតឡើងនៅបុរីកីឡាមិនមែនជាព្រឹត្តការណ៍ដែលមានលក្ខណៈខុសប្លែកពីគេឡើយ ។ នៅប្រទេសកម្ពុជា សហគមន៍ប្រជាពលរដ្ឋក្រីក្រតែងតែត្រូវបានគេបណ្តេញចេញពីផ្ទះសម្បែងរបស់ខ្លួនដោយបង្ខំ ពីសំណាក់ក្រុមហ៊ុន ដែលបានទទួលដីសម្បទានពី រ.ដ.ក ដោយមានត្រឹមការពិគ្រោះយោបល់ ការសងការខូចខាត ឬយន្តការផ្តល់ប្រាក់សំណងបន្តិចបន្តួច ឬគ្មានទល់តែសោះ ។ យោងតាមអង្គការលើកលែងទោសអន្តរជាតិ ប្រជាពលរដ្ឋក្នុងទីក្រុងភ្នំពេញប្រមាណ១០ភាគរយត្រូវបានគេបណ្តេញចេញពីលំនៅដ្ឋានដោយបង្ខំ ក្នុងចន្លោះឆ្នាំ១៩៩០ និងឆ្នាំ២០១១ ដែលការបណ្តេញចេញទាំងនេះជាញឹកញាប់បណ្តាលមកពីគម្រោងអភិវឌ្ឍន៍ និងជម្លោះដីធ្លី ។ ដោយក្រុមហ៊ុន និងរ.ដ.ក កម្រផ្តល់លំនៅដ្ឋានអចិន្ត្រៃយ៍ និងសេវាកម្មដល់ប្រជាពលរដ្ឋដែលត្រូវគេបណ្តេញចេញ ជាញឹកញាប់ពួកគេមិនមានជម្រើសអ្វីក្រៅពីរស់នៅក្នុងស្ថានភាពប្រហាក់ប្រហែលនឹងស្ថានភាពដែលអ្នករស់នៅក្នុងបុរីកីឡាជួបប្រទះក្នុងតំបន់ដែលពួកគេតាំងទីលំនៅថ្មីឡើយ ។

សេចក្តីសន្និដ្ឋាន និងអនុសាសន៍

យោងតាមច្បាប់ជាតិ និងអន្តរជាតិ ដីសម្បទានអាចផ្តល់ជូនបានដោយមានការពិគ្រោះយោបល់ជាមុន ជាមួយនឹងអ្នកដែលទទួលរងផលប៉ះពាល់ រួមមានអ្នកដែលត្រូវគេបណ្តេញចេញពីផ្ទះសម្បែងរបស់ខ្លួន ព្រមទាំងផ្តល់ឲ្យនូវសំណង លំនៅដ្ឋាន និងយន្តការប្រាក់សំណងសមស្រប ។ មាត្រដ្ឋានអន្តរជាតិបានបង្ហាញយ៉ាងច្បាស់អំពីដំណើរការនៃការបណ្តេញប្រជាពលរដ្ឋចេញពីផ្ទះ និងកំណត់ល័ក្ខខ័ណ្ឌនៃលំនៅដ្ឋានសមស្របសម្រាប់អ្នកដែលត្រូវគេបណ្តេញចេញ ។ គោលការណ៍ណែនាំស្តីពីសិទ្ធិមនុស្ស និងក្រុមហ៊ុនរបស់អង្គការសហប្រជាជាតិ ផ្តល់ការណែនាំបន្ថែម ដោយមិនត្រឹមតែបានបញ្ជាក់យ៉ាងច្បាស់ថា ក្រុមហ៊ុនត្រូវគោរពតាមច្បាប់ទាំងឡាយដែលមានចែង និងគោរពសិទ្ធិមនុស្សទេ ហើយថែមទាំងបានកំណត់ថា រដ្ឋត្រូវការពារប្រជាពលរដ្ឋរបស់ខ្លួនពីការរំលោភបំពានសិទ្ធិមនុស្ស រួមមានសកម្មភាពរំលោភបំពានពីសំណាក់ក្រុមហ៊ុន និងសហគ្រាស ។ ទោះជាយ៉ាងណាក៏ដោយ ក្រុមហ៊ុន និងរ.ដ.ក មិនបានគោរពតាមច្បាប់ និងមាត្រដ្ឋានទាំងនេះបន្តិចសោះឡើយ ហើយព្រមទាំងមិនបានចាត់វិធានការជាដុំកំភួន ដើម្បីធានាថាសិទ្ធិរបស់ជនរងគ្រោះ ដែលត្រូវបានគេបណ្តេញចេញពីលំនៅដ្ឋានត្រូវបានគោរពឡើយ ។

ការបណ្តេញចេញដោយបង្ខំពីតំបន់បុរីកីឡាបង្ហាញឲ្យឃើញនូវគំរូមួយក្នុងប្រទេសកម្ពុជា ដែលរ.ដ.ក មិនត្រឹមតែខកខានមិនបានបំពេញតួនាទីរបស់ខ្លួន ក្នុងការការពារប្រជាពលរដ្ឋពីការរំលោភបំពានសិទ្ធិមនុស្ស ដែលបង្កឡើងដោយក្រុមហ៊ុនឡើយ ហើយថែមទាំងបានសម្របសម្រួលឲ្យមានការរំលោភបំពានបែបនេះ ដោយបានផ្តល់មន្ត្រីប្រដាប់អាវុធ ដើម្បីជួយបណ្តេញ និងកំទេច ព្រមទាំងចាប់ខ្លួនអ្នកប្រឆាំងតវ៉ាថែមទៀតផង ។ រ.ដ.ក ត្រូវដោះស្រាយជាបន្ទាន់នូវរឿងបត្តិមនុស្សធម៌ក្នុងតំបន់បុរីកីឡា និងតំបន់ដែលប្រជាពលរដ្ឋតាំងទីលំនៅថ្មី ដោយផ្តល់ដំណោះស្រាយ និងសំណងគ្រប់គ្រាន់ដល់គ្រួសារដែលត្រូវបានគេបណ្តេញចេញដោយបង្ខំ ជាពិសេសការផ្តល់ជូនលំនៅដ្ឋានអចិន្ត្រៃយ៍ឲ្យបានគ្រប់គ្រាន់ ដូចបានសន្យាក្នុងល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងរវាង រ.ដ.ក និងក្រុមហ៊ុនជានអ៊ីមិច ។ បើមិនដូច្នោះទេ ប្រជាពលរដ្ឋស្លូតត្រង់កាន់តែច្រើននឹងស្លាប់ដោយមិនត្រូវបានគេយកចិត្តទុកដាក់ក្នុងភាពលំបាក និងវេទនា ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង លោក អ៊ុច ឡេង តាមរយៈទូរស័ព្ទ (+៨៥៥ (0) ១៦ ៧០ ៥៥ ៦៧) ឬអ៊ីម៉ែល ouchleng@cchrcambodia.org **ឬ លោក រ៉ូប៊ឺត ហ្វីនជ៍ (+៨៥៥ (0) ៧៨ ៨០ ៩៩ ៦០) ឬអ៊ីម៉ែល** robert.finch@cchrcambodia.org